ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ៖ បព ១៩/២០២៦ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# ការផ្តល់ជំនួយមនុស្សធម៌ពីរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ សម្រាប់ជំនួយមនុស្សធម៌ចំនួនប្រាំរយពាន់ដុល្លារអាម៉េរិក (៥០០.០០០ ដុល្លារអាម៉េរិក) តាមរយៈអង្គការយូនីសេហ្វ (UNICEF) ដែលកំពុងប្រតិបត្តិការក្នុងមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការមនុស្សធម៌នាពេលថ្មីៗនេះ ដែលបង្កឡើងដោយជម្លោះព្រំដែនកម្ពុជា-ថៃ។

ការចូលរួមចំណែកនេះ គឺជាសក្ខីភាពបញ្ជាក់ពីសាមគ្គីភាព និងសមានចិត្តពីរដ្ឋាភិបាល និងប្រជាជននៃសាធារណរដ្ឋកូរ៉េ ចំពោះរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា។ ជំនួយនេះ ក៏បានគូសបញ្ជាក់បន្ថែមទៀតនូវចំណងមិត្តភាពយូរអង្វែង កិច្ចសហប្រតិបត្តិការដែលកំពុងរីកចម្រើន និងសារៈសំខាន់ដែលភាគីទាំងពីរផ្តល់ដល់ភាពជាដៃគូយុទ្ធសាស្ត្ររវាងប្រទេសទាំងពីរ។

ជាមួយគ្នានេះ កម្ពុជាក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបណ្តាប្រទេស និងអង្គការទាំងអស់ដែលបានផ្តល់ជំនួយ និងការគាំទ្រដល់ជនភៀសសឹកកម្ពុជាក្នុងអំឡុងពេលដ៏លំបាកនេះ៕

ថ្ងៃពុធ ៩រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០២៦

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh